## គម្រូនៃការដេញដោល ក្នុងដំណើរការក្តីព្រហ្មទណ្ឌ (adversary model)

បញ្ញាវន្ត Damaska បានបែងចែកនូវគម្រូពាក់ព័ន្ធនឹងការរៀបចំអនុវត្តអំណាចរបស់រដ្ឋ ដែលក្នុងនោះមានគម្រូដេញដោលនេះ ហើយគាត់បានញែកគម្រូនេះ ខុសពីគម្រូអនុវត្តគោលនយោបាយក្នុង (policy-implementing model) ប្រទេសប្រកាន់ប្រព័ន្ធស៊ីវិលឡ (civil law)។

គម្រូដេញដោលនេះ ត្រូវបានអនុវត្តក្នុងប្រព័ន្ធច្បាប់ព្រហ្មទណ្ឌជាតិនិងអន្តរជាតិ។ គម្រូនេះមាននីតិវិធីជាក់លាក់ក្នុងការទទួលឬមិនទទួលយកភស្តុតាង (admissibility of evidence) (តាមរយៈការងាររបស់ក្រុមប្រឹក្សាជំនុំជម្រះ) (jury) ហើយចៅក្រម អាចបញ្ជាឲ្យបង្កើតភស្តុតាងបន្ថែម ដោយខ្លួនឯង (*proprio motus*) និង ការទទួលយកនូវការសារភាពពិរុទ្ធភាព (guilty plea)។

ទាក់ទងនឹងភាគីក្នុងដំណើរការក្តី ប្រព័ន្ធនេះអនុញ្ញាតឲ្យភាគី អាចគ្រប់គ្រងដំណើរការបាន តាំងពីការចាប់ផ្តើមដំបូង។ នេះដូចជាករណី guilty plea ដែលជាលទ្ធភាពសម្រាប់ការចរចាររវាងភាគី។ ពាក់ព័ន្ធនឹងដំណើរការស្វែងរកអង្គហេតុ (fact finding) ភាគីទាំងសងខាង អាចបង្ហាញភស្តុតាង ហើយដែលគោលការណ៍សមភាព (equality of arms) នៃភាគី ពាក់ព័ន្ធយ៉ាងខ្លាំងក្នុងរឿងនេះ។ គម្រូនេះមិនគាំទ្រនូវសវនាការមិនចំពោះមុខ (trial in *absentia*) ច្រើនទេ ដោយសារ មានការតម្រូវឲ្យភាគីមានអ្នកតំណាងគ្រប់គ្រាន់ និង អាចស្នើសុំដល់ស្ថាប័នតុលាការក្នុងការគាំទ្រសកម្មភាពស្វែងរកអង្គហេតុ។ ពាក់ព័ន្ធនឹងតួនាទីរបស់ចៅក្រមក្នុងពេលសវនាការ ចៅក្រមពឹងតែលើភស្តុតាងដែលបង្ហាញក្នុងពេលសវនាការ។

មានហេតុផលចំនួនពីរ ដែលនាំឲ្យរដ្ឋប្រកាន់យកគម្រូនេះ៖ ទី១.វានាំឲ្យមានលទ្ធផលប្រកប ដោយយុត្តិធម៌ និងទី២.ការទាមទារនូវការបង្ហាញភស្តុតាងនៅក្នុងសវនាការ ដែលវាជួយដល់តម្លាភាពសម្រាប់សាធារណជន (Antonio Cassese, the Oxford Companion to International Criminal Justice, 2009, pp. 230-234)។